លេខ៖ D309/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 07 / 2017
ម៉ោង (Time/Heure): 13:00
មន្ត្រីមទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

| | |
|---|---|
| ចំពោះមុខ ៖ | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ |
| ភាសា ៖ | អង់គ្លេស & ខ្មែរ |
| ចំណាត់ថ្នាក់ឯកសារ ៖ | សម្ងាត់ |

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អ៊ឹម ចែម**
ប៊ិត សៀងលឹម
Wayne JORDASH

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES NZEPA
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ យើងបានចេញ*ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំដកចេញព័ត៌មាននិងព័ត៌មានសាធារណៈ*ដែលនៅក្នុងដីកានេះ យើងបានធ្វើការបដិសេធផ្សេងៗរួមមានការបដិសេធសំណើរបស់មេធាវីការពារក្ដី អ៊ឹម ចែម("មេធាវីការពារក្ដី") សុំបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ចេញផ្សាយការដកចេញវិញនូវព័ត៌មានខ្លះពីសេចក្ដីសង្ខេបជាសាធារណៈនៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ដែលបានដាក់យោងតាមវិធានផ្ទៃក្នុង ៦៦(៥) ហើយយើងក៏បានបង្គាប់ឱ្យដាក់សំណៅជាសាធារណៈដោយមានការកោសលុបនៃសំណើនេះនិងចម្លើយតបរបស់ ស.ព.អ ("ដីកាសម្រេចលើការដកចេញព័ត៌មានខ្លះ")[1]។

២. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ យើងបានចេញ *ដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច)* ដោយលើកលែងការចោទប្រកាន់លើ អ៊ឹម ចែម ហើយជូនដំណឹងភាគីទាំងអស់ថា សំអាងហេតុពេញលេញសម្រាប់ការលើកលែងការចោទប្រកាន់នេះនឹងចេញដាច់ដោយឡែក[2]។ នៅក្នុងសេចក្ដីប្រកាសព័ត៌មានរបស់យើងនៅថ្ងៃដដែលនេះ យើងបានបង្ហាញថា យើងនឹងដាក់សំណៅជាសាធារណៈនៃសំអាងហេតុអង្គច្បាប់សំខាន់ៗទាំងនេះ[3]។

៣. នៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើស្នើថា សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចលើការដកចេញព័ត៌មានខ្លះ គួរដាក់ជាសាធារណៈ ("សំណើ")[4]។

៤. នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧ មេធាវីការពារក្ដី បានដាក់សារណាតបទៅនឹងសំណើ ("សារណាតប")[5]។

---

[1] សំណុំរឿង០០៤/១ ឯកសារ D306/2 *ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំដកចេញព័ត៌មាននិងព័ត៌មានសាធារណៈ* ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧។

[2] សំណុំរឿង ០០៤/១ ឯកសារ D308 *ដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច)* ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[3] អាចរកបានតាមរយៈ៖ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-dismiss-case-against-im-chaem។

[4] សំណុំរឿង ០០៤/១ ឯកសារ D309 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើថា សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ សចស ត្រូវដាក់ជាសាធារណៈ* ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៧។

៥. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ យើងបានចេញសំណៅសម្ងាត់ និងសំណៅជាសាធារណៈ ដោយមានការកោសលុបនៃ*ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ)*[6]។

## II. សារណា

### ក. សំណើ

៦. ស.ព.អ អះអាងថា គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលលើកឡើងថា ដីកាដំណោះស្រាយមិនត្រូវដាក់ជាសាធារណៈទេ មិនថាលើកលែងការចោទប្រកាន់ ឬក៏បញ្ជូនទៅជំនុំជម្រះទេ។ ស.ព.អ អះអាងថា វិធានផ្ទៃក្នុង ៥៦ ដែលចែងថា *"ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ"* គឺមិនមែនចង់មានន័យថា លទ្ធផលចុងក្រោយនៃការស៊ើបសួរត្រូវរក្សាការសម្ងាត់ឡើយ។ ជាងនេះទៀត វិធានផ្ទៃក្នុង ៥៦(២)(ក) ចែងអំពីការផ្តល់ព័ត៌មាននៅក្នុងអំឡុងពេលស៊ើបសួរ *"ដើម្បីធ្វើឲ្យសាធារណជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី"* ដោយរំពឹងទុកថានឹងមានការផ្តល់ព័ត៌មាននៅក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរដោយសម្ងាត់[7]។

៧. ស.ព.អ អះអាងថា មូលហេតុដែលចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃដីកាដំណោះស្រាយដែលបញ្ជូនសំណុំរឿងទៅជំនុំជម្រះ (ធ្លាប់អនុវត្តពីមុនរួចហើយ) និងដីកាដំណោះស្រាយដែលលើកលែងការចោទប្រកាន់នោះ ជាគោលការណ៍ គឺជាករណីដូចគ្នាដើម្បីឲ្យមានតម្លាភាព និងធានាថា សាធារណជនបានដឹងអំពីកិច្ចដំណើរការនីតិវិធីតុលាការរបស់ អ.វ.ត.ក[8]។

៨. ស.ព.អ អះអាងថែមទៀតថា ការរក្សាទុកសំអាងហេតុទាំងនោះជាការសម្ងាត់ គឺជាគំរូអវិជ្ជមានមួយសម្រាប់យុត្តាធិការរបស់តុលាការជាតិ ហើយជំរុញឲ្យមានការរិះគន់ អ.វ.ត.ក

---

[5] សំណុំរឿង ០០៤/១ ឯកសារ D309/1 *ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សេចក្តីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ* ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧។

[6] សំណុំរឿង ០០៤/១ ឯកសារ D308/2 *ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ)* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

[7] សំណើ កថាខណ្ឌ ៣។

[8] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥។

01508092



ពីភាគីខាងក្រៅ[9]។ ស.ព.អ គួសបញ្ជាក់ពីយុត្តិសាស្ត្រអន្តរជាតិដែលសង្កត់ធ្ងន់លើសារៈសំខាន់នៃតម្លាភាពដែលជំរុញឱ្យមានជំនឿទុកចិត្តពីសាធារណជនលើកិច្ចការរដ្ឋបាលតុលាការ និងបញ្ជាក់ថា ការដឹងឮជាសាធារណៈត្រូវចាត់ទុកថាជាការធានាឱ្យមានភាពយុត្តិធម៌នៅក្នុងការជំនុំជម្រះក្តី[10]។

៩. ចំពោះដីកាសម្រេចលើការដកចេញព័ត៌មានខ្លះ ស.ព.អ គួសបញ្ជាក់ថា សំណើរបស់មេធាវីការពារក្តី និងចម្លើយរបស់ ស.ព.អ បានដាក់ជាសំណៅជាសាធារណៈដោយមានការកោសលុប ហើយអះអាងទៀតថា ពុំមានមូលហេតុដែលត្រូវរក្សាទុកដីកាសម្រេចលើការដកចេញព័ត៌មានខ្លះជាការសម្ងាត់ទេ ពីព្រោះថា ដីកាសម្រេចនេះមិនមានព័ត៌មានសម្ងាត់ទេ[11]។

## ខ. សារណាតប

១០. មេធាវីការពារក្តី មិនជំទាស់នឹងការដាក់ដីកាសម្រេចលើការដកចេញព័ត៌មានខ្លះជាសាធារណៈទេ[12]។

១១. ប៉ុន្តែ មេធាវីការពារក្តី ជំទាស់នឹងសំណើសុំឱ្យចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃដីកាដំណោះស្រាយ ដោយផ្អែកលើមូលដ្ឋានថា សំណើនេះមិនទាន់ដល់ពេលទេ។ មេធាវីការពារក្តី អះអាងថា ពេលតែមួយគត់ដែលលែងមានមូលហេតុធ្វើចំណាត់ថ្នាក់ឯកសារណាមួយជាឯកសារសម្ងាត់នោះ គឺពេលដែល ស.ច.ស ពិចារណាធ្វើចំណាត់ថ្នាក់ឯកសារនោះឡើងវិញថាជាឯកសារសាធារណៈ។ ជាងនេះទៀត មុនពេលចេញសំអាងហេតុពេញលេញលើកលែងការចោទប្រកាន់នោះ ទាំង ស.ព.អ ទាំង មេធាវីការពារក្តី មិនស្ថិតនៅក្នុងតួនាទីដែលអាចដាក់ទឡ្ហីករណ៍ដែលទទួលបានព័ត៌មានគ្រប់គ្រាន់អំពីព័ត៌មានដែលអាចដាក់ជាសាធារណៈបានឡើយ។ ចុងក្រោយ មេធាវីការពារក្តីអះអាងថា ការរង់ចាំរហូតដល់ពេលមានសំអាងហេតុច្បាស់លាស់ និងជាក់ស្តែងនោះនឹងធានាថា ការដាក់បង្ហាញព័ត៌មានជា

[9] ដូចដើងទំព័រខាងលើ ៦។

[10] ដូចដើងទំព័រខាងលើ ៧-៨។

[11] សារណាតប កថាខណ្ឌ ៩។

[12] សារណាតប កថាខណ្ឌ ២។

01508093



សាធារណៈណាមួយនឹងទទួលបានតុល្យភាពត្រឹមត្រូវរវាងផលប្រយោជន៍របស់ភាគីទាំងអស់ជាមួយនឹងកិច្ចការរដ្ឋបាលតុលាការ[13]។

## III. ពិភាក្សា

១២. នៅក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ជាពិសេសវិធានផ្ទៃក្នុង ៥៦ យើងមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការដោះស្រាយលើបញ្ហារក្សាការសម្ងាត់នៅក្នុងអំឡុងពេលស៊ើបសួរ[14] រាប់បញ្ចូលទាំងការធ្វើចំណាត់ថ្នាក់ឯកសារ និងការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ[15] ព្រមទាំងការចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃឯកសារសម្ងាត់ ឬឯកសារសម្ងាត់បំផុត[16]។

១៣. វិធានផ្ទៃក្នុង ៥៦ ចែងថា ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ ប៉ុន្តែ ចែងថា ស.ច.ស អាចចេញព័ត៌មានបែបនេះពាក់ព័ន្ធទៅនឹងសំណុំរឿងប្រសិនបើ ស.ច.ស យល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឱ្យសាធារណជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬដើម្បីកែតម្រូវព័ត៌មានមិនពិត ឬព័ត៌មាននាំឱ្យមានការភ័ន្តច្រឡំ[17]។ យើងយល់ស្របតាម ស.ព.អ ដែលថា វិធានផ្ទៃក្នុង ៥៦ មិនតម្រូវថា លទ្ធផលចុងក្រោយនៃការស៊ើបសួរត្រូវរក្សាការសម្ងាត់ឡើយ។ ប៉ុន្តែដំណាក់ស៊ើបសួរបានបញ្ចប់ជាផ្លូវការតែពេលណាដែល អ.ប.ជ បានសម្រេចលើបណ្ដឹងឧទ្ធរណ៍ណាមួយដែលជំទាស់ដីកាដំណោះស្រាយតែប៉ុណ្ណោះ(ទោះបីជាយើងអស់ភារកិច្ចហើយក្រោយពីបានចេញដីកាដំណោះស្រាយ)។ តាមឆន្ទានុសិទ្ធិរបស់ ស.ច.ស ឬក៏តាមសំណើរបស់ភាគីណាមួយ ស.ច.ស អាចចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃឯកសារនានា ហើយពិតណាស់ ស.ច.ស ធ្លាប់បានធ្វើដូច្នេះហើយដោយ

---

[13] ដូចដើងទំព័រខាងលើ កថាខណ្ឌ ២, ៨-១០។

[14] សំណុំរឿង ០០៤ ឯកសារ D284/1/4 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើចម្លើយបត ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៣។

[15] សេចក្ដីណែនាំអនុវត្តន៍ស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ២ មាត្រា ៤(ក)។ សេចក្ដីណែនាំអនុវត្តន៍ស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ៨ មាត្រា ៣.១២, ៣.១៤។

[16] សេចក្ដីណែនាំអនុវត្តន៍ស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ២ មាត្រា ៩.២, ៩.៣។

[17] វិធានផ្ទៃក្នុង ៥៦(១), (២)(ក)។

បានចេញដីកាសម្រេចមួយចំនួន[18]។ យ៉ាងណាក៏ដោយត្រូវតែចងចាំថា គ្មានអ្វីដែលតម្រូវឱ្យយើងចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃឯកសារណាមួយឡើយ។ ហេតុនេះ ខណៈដែល ស.ព.អ ដកស្រង់នូវឧទាហរណ៍មួយអំពីការចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃដីកាដំណោះស្រាយសំណុំរឿង ០០២ ស.ច.ស ក៏បានសម្រេចមិនបង្ហាញជាសាធារណៈនៅក្នុងសំណុំរឿងដូចគ្នានេះដែរអំពីដីកាលើកលែងការចោទប្រកាន់លើ ឌុច នៅក្នុងសំណុំរឿងនោះ។

១៤. យើងធ្លាប់បានបញ្ជាក់ថា សំអាងហេតុសម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់លើ អ៊ឹម ចែម ឱ្យតែពាក់ព័ន្ធនឹងអង្គសេចក្តីនៃបទចោទ នឹងនៅរក្សាការសម្ងាត់[19]។ ហេតុនេះ យើងបានសម្រេចចេញសំណៅជាសាធារណៈដោយមានការកោសលុបដែលស្របតាមជំហរពីមុនរបស់យើងក្នុងការរក្សាការសម្ងាត់អំពីអង្គសេចក្តីនៃបទចោទទាំងនោះ។

១៥. ចំពោះមតិយោបល់របស់ ស.ព.អ អំពីការរិះគន់ពីភាគីខាងក្រៅមកលើ អ.វ.ត.ក និងការបង្កើតជាគំរូអាក្រក់សម្រាប់យុត្តាធិការរបស់តុលាការជាតិនោះ យើងសូមរំឭកភាគីទាំងអស់ថា កម្រិតតម្លាភាពដែលត្រូវការជាចាំបាច់ត្រូវបានកំណត់រួចហើយនៅក្នុងច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង ច្បាប់បន្ថែមផ្សេងទៀតរបស់ប្រទេសកម្ពុជា និងវិធានច្បាប់អន្តរជាតិជាធរមាន។ ការលើកឡើងអំពីបរិបទជំនុំជម្រះក្តីជាសាធារណៈមិនបានជួយជាប្រយោជន៍ណាមួយទេសម្រាប់ដំណាក់កាលស៊ើបសួរដោយសម្ងាត់។ នៅក្នុងយុត្តាធិការជាច្រើននៃប្រព័ន្ធច្បាប់ស៊ីវិលឡូ មានការតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈអំពីដីកាបញ្ជូនទៅជំនុំជម្រះតែពេលដែលកិច្ចដំណើរការនីតិវិធីឈានដល់សវនាការជាសាធារណៈតែប៉ុណ្ណោះ។ ប្រព័ន្ធច្បាប់កុំមិនឡូមានវិធីសាស្ត្រមិនសូវតឹងរឹងចំពោះសិទ្ធិឯកជនរបស់ជនសង្ស័យ ដោយសារប្រព័ន្ធផ្សព្វផ្សាយអាចចេញសេចក្តីរាយការណ៍ដែលបង្ហាញឈ្មោះ ថែមទាំងអាសយដ្ឋានរបស់ជនសង្ស័យទៀតផង ជួនកាលចេញផ្សាយតែក្នុងរយៈពេលប៉ុន្មានម៉ោងបន្ទាប់ពីនគរបាលធ្វើការចោទប្រកាន់ជាលើកដំបូងតែប៉ុណ្ណោះ (ជារឿយៗ ការចេញផ្សាយអាចធ្វើទៅបានដោយសារមានជំនួយពី

---

[18] សេចក្តីណែនាំអនុវត្តន៍ស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ២ មាត្រា ៩.២, ៩.៣។

[19] អាចរកបានតាមរយៈ៖ https://www.eccc.gov.kh/sites/default/files/media/Press%20Release%20by%20the%20Office%20of%20the%20Co-Investigating%20Judges%2022%20Februay%202017%20English.pdf។



CO-INVESTIGATING ... *ECCC*CETC*

01508095



នគរបាលតាមរយៈអ្វីដែលគេហៅថា "កំណត់ហេតុនគរបាល")។ អាចមានភាពខុសគ្នារវាងវិធីសាស្ត្រមិនសូវតឹងរឹងនេះជាមួយនឹងវិធីសាស្ត្រតឹងរឹងជាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ។ ប្រទេសកម្ពុជា ស្ថិតនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូដែលប្រើប្រាស់វិធីសាស្ត្រតឹងរឹងនេះ។

១៦. ត្រង់ចំណុចនេះ យើងយោងលើមាត្រា ៨៣(៤) និង ១២១(៥)នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ បូករួមជាមួយនឹងមាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែលកំណត់ថា ការរំលោភលើការសម្ងាត់នៃការស៊ើបសួរគឺជាបទល្មើស។ ច្បាប់កម្ពុជាមិនបានចែងទាល់តែសោះអំពីការផ្សព្វផ្សាយជាសាធារណៈអំពីដីកាដំណោះស្រាយដោយមានការកោសលុប ឬក៏មិនមានការកោសលុប។ បទប្បញ្ញត្តិស្រដៀងគ្នាទាក់ទងនឹងការផ្សព្វផ្សាយជាសាធារណៈមុនពេលជំនុំជម្រះក្តី ក៏មានចែងផងដែរនៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិលប្រទេសផ្សេងទៀត ឧទាហរណ៍ ដូចជា ប្រទេសអាល្លឺម៉ង់ ស្វីស និងបារាំង ជាដើម[20]។

១៧. មេធាវីការពារក្តី ស្វែងរកឱកាសបញ្ចេញមតិយោបល់អំពីអ្វីដែលគួរផ្សព្វផ្សាយជាសាធារណៈនៅក្នុង*ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ)* ប៉ុន្តែ មិនមានសិទ្ធិបែបនេះទេទាក់ទងនឹងសំណៅជាសាធារណៈដោយមានការកោសលុបនៃឯកសារណាមួយ។ កាលៈទេសៈដែលភាគីទាំងអស់មានសិទ្ធិបញ្ចេញមតិយោបល់ ទាក់ទងនឹងការអនុវត្តឆន្ទានុសិទ្ធិរបស់យើងលើការសម្ងាត់នៃការស៊ើបសួរ គឺត្រូវកម្រិតនៅត្រឹមករណីដែលយើងស្នើសុំ (ក) អនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយ ឬអ្នកដទៃទៀតដែលមិនមានជាភាគីចូលពិនិត្យការស៊ើបសួរ[21] ឬ (ខ) ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ[22]។ ការរៀបចំសំណៅជាសាធារណៈដោយមានការកោសលុប ស្រប

---

[20] *សូមមើល* ផ្នែក ៣៥៣ ឃ នៃក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ដែលកំណត់ថាជាបទល្មើសប្រសិនបើផ្សព្វផ្សាយជាសាធារណៈអំពី "ពាក្យពេចន៍ដើមពីផ្នែកខ្លះដែលសំខាន់ ឬផ្នែកទាំងអស់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬឯកសារផ្លូវការផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយ ជានីតិវិធីដែលត្រូវដាក់ទោសជាប្រាក់ពិន័យ ឬជានីតិវិធីដាក់ទោសវិន័យ *មុនពេលដែលព័ត៌មានទាំងនោះបានលើកឡើងនៅក្នុងសវនាការសាធារណៈ* ឬមុនពេលដែលកិច្ចដំណើរការនីតិវិធីនោះបានបញ្ចប់")(យើងសង្កត់ន័យបន្ថែម)។ *សូមមើលផងដែរ* មាត្រា ២២៦-១៣ នៃក្រមព្រហ្មទណ្ឌនៃសាធារណរដ្ឋបារាំង និងមាត្រា ២៩៣ នៃក្រមព្រហ្មទណ្ឌស្វីស។ *សូមមើលថែមទៀត* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Bédat តទល់នឹងស្វីស* ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២២ ដែលក្នុងនេះមានការសង្កេតឃើញថា ការបង្ហាញព័ត៌មានដែលស្ថិតនៅក្នុងការអាថ៌កំបាំងនៃការស៊ើបសួរព្រហ្មទណ្ឌ ត្រូវដាក់ទោសនៅក្នុងរដ្ឋជាសមាជិកចំនួន ៣០ នៅក្រុមប្រឹក្សាអឺរ៉ុប។

[21] វិធានផ្ទៃក្នុង ៥៦(២)(ខ)។

[22] សេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ៨ មាត្រា ៣.១៤។

តាមវិធានផ្ទៃក្នុង ៥៦ និងសេចក្ដីណែនាំអនុវត្តដែលពាក់ព័ន្ធ[23] គឺស្ថិតនៅក្នុងឆន្ទានុសិទ្ធិទាំងស្រុងរបស់យើង។

១៨. ហេតុនេះ យើងបានណែនាំឱ្យរៀបចំសំណៅជាសាធារណៈដោយមានការកោសលុបនៃ*ដីកាដំណោះស្រាយ(ផ្នែកសំអាងហេតុ)* ដែលបានចេញនៅថ្ងៃនេះ ដូច្នេះធ្វើឱ្យផ្នែកខ្លះនៃសំណើទុកជាមោឃៈ។

១៩. ចំពោះដីកាសម្រេចលើការដកចេញព័ត៌មានខ្លះ យើងយល់ស្របតាម ស.ព.អ ដែលថាមិនមានមូលហេតុដែលមិនឱ្យដាក់ដីកាសម្រេចនេះជាសាធារណៈទេ ហើយដោយកត់សម្គាល់ថា មេធាវីការពារក្ដីមិនជំទាស់នឹងការធ្វើដូច្នេះទេ ទើបយើងអនុញ្ញាតតាមសំណើត្រង់ចំណុចនេះ។ យើងបានត្រួតពិនិត្យដីកាសម្រេចលើការដកចេញព័ត៌មានខ្លះ ហើយជឿថា មិនតម្រូវឱ្យមានការកោសលុបទេ។ ហេតុនេះ ដីកាសម្រេចលើការដកចេញព័ត៌មានខ្លះ នឹងត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញជាឯកសារសាធារណៈ។

**តាមសំអាងហេតុខាងលើ យើង[24]៖**

២០. **ប្រកាស** ថា សំណើសុំចេញសំណៅជាសាធារណៈដោយមានការកោសលុបនៃ*ដីកាដំណោះស្រាយ (ផ្នែកសំអាងហេតុ)* ទុកជាមោឃៈ។

២១. **អនុញ្ញាតតាម** សំណើសុំដាក់ដីកាសម្រេចលើការដកចេញព័ត៌មានខ្លះជាសាធារណៈ។

២២. **បង្គាប់** ក្រឡាបញ្ជី ក.ស.ច.ស ត្រូវធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដីកាសម្រេចលើការដកចេញព័ត៌មានខ្លះ ទៅជាឯកសារសាធារណៈ។

---

[23] សេចក្ដីណែនាំអនុវត្តន៍ស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី ២។

[24] ខណៈដែលសហចៅក្រមស៊ើបអង្កេតទាំងពីរបានចេញសេចក្ដីជូនដំណឹងនេះរួមគ្នា សហចៅក្រមស៊ើបអង្កេតជាតិកត់សម្គាល់ទុកជាឯកសារថា ឯកសារទាំងឡាយ នៃសំណុំរឿង ០០៤ ត្រូវចុះលេខរៀងបន្តពីលេខឯកសារចុងក្រោយមុនពេលការលាលែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk ដោយមិនរាប់បញ្ចូលឯកសារទាំងអស់ដែលត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper-Ansermet។





CC INVESTIGATING ... E.C.C.C * C.E.T.C

០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ D309/2

ភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**
Co-Investigating Judges
Co-juge d'instruction

**ចៅក្រម យូ ប៊ុនឡេង** **ចៅក្រម Michael BOHLANDER**